**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានីភ្នំពេញ**
**ខណ្ឌ សែនសុខ**
**សង្កាត់ ទឹកថ្លា**
លេខ......០០៤ ស.ស.ទក

## សេចក្ដីជូនដំណឹង

យើងជាចៅសង្កាត់ ទឹកថ្លា សូមជម្រាបជូនបងប្អូនប្រជាពលរដ្ឋ ដែលរស់នៅក្នុងសង្កាត់ទឹកថ្លាទាំងមូល អោយបានជ្រាបថា: ដោយបានមើលឃើញពីផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដែលបណ្ដាលមកពីការប្រើប្រាស់គ្រឿងស្រវឹង ចំពោះសុខភាពប្រជាពលរដ្ឋ និងសុខភាពសាធារណៈ ហើយដើម្បីលើកទឹកចិត្តអោយមានការកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹង និងលើកទឹកចិត្តចំពោះសកម្មភាពផ្សព្វផ្សាយនានាដូចតទៅៈ

**ប្រការ១ៈ** រាល់សកម្មភាពទាំងឡាយណា ដែលលើកទឹកចិត្តអោយមានការកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹងនៅក្នុងសង្កាត់ត្រូវបានលើកទឹកចិត្ត និងសហការទៅវិញទៅមកជាមួយសង្កាត់ នឹងដៃគូរអភិវឌ្ឍន៍។

**ប្រការ២ៈ** សូមកុំបើកបរយានយន្តគ្រប់ប្រភេទ នៅពេលពិសារគ្រឿងស្រវឹង។

**ប្រការ៣ៈ** ប្រើប្រាស់គ្រឿងស្រវឹង សូមកុំបង្កអោយមានការរំខានចំពោះអ្នកដទៃ។

**ប្រការ៤ៈ** ហាមប្រើប្រាស់គ្រឿងស្រវឹង រួចទៅបង្កអោយមានអំពើហិង្សា ការបង្កសំលេងរំខាន ឬប្រព្រឹត្តអំពើណាមួយដែលប៉ះពាល់ដល់អ្នកដទៃ និងសង្គមជាតិ។

**ប្រការ៥ៈ** ការបញ្ឈប់ ឬកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹងបស់បងប្អូនប្រជាពលរដ្ឋនៅក្នុងសង្កាត់ត្រូវបានលើកទឹកចិត្ត និងគាំទ្រ។

សេចក្ដីជូនដំណឹងខាងលើនេះជាការជូនជាពត៌មាន ដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងសង្កាត់អោយបានជ្រួតជ្រាប ដើម្បីលើកទឹកចិត្តដល់បងប្អូនប្រជាពលរដ្ឋក្នុងការបញ្ឈប់ ឬកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹង និងចូលរួមការផ្សព្វផ្សាយនានាពីផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងស្រវឹង។

សង្កាត់ទឹកថ្លា,ថ្ងៃទី២៧....ខែ.មេសា..ឆ្នាំ២០១៦
**ចៅសង្កាត់ទឹកថ្លា**

ភន់-ណារិន